**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ អ៊ឹម ចែម

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៤

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Aug-2014, 12:15
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សម្ងាត់បំផុត/Strictly Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឲ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

ប៊ិត ស៊ាងលីម

John R.W.D. JONES QC

**<u>ចម្លងជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមវិធាន ៤៨ និង ៧៦(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សូមដាក់សំណើជាបន្ទាន់សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពដីកាកោះហៅឱ្យបង្ហាញខ្លួនជាលើកដំបូង ("ដីកាកោះ អ៊ឹម ចែម") និងស្នើសុំឱ្យធ្វើមោឃភាពដីកាកោះសហមេធាវីការពារក្តីឱ្យចូលរួមនៅក្នុងការបង្ហាញខ្លួនលើកដំបូងរបស់អ្នកស្រី អ៊ឹម ចែម។ សំណើនេះមានភាពចាំបាច់ ពីព្រោះថាៈ ក) ដីកាកោះត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ប៉ុណ្ណោះ ខ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានបំណងចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយមិនផ្តល់ឱកាសឱ្យអ្នកស្រីបានធ្វើការតតាំង និង គ) សហចៅក្រមស៊ើបអង្កេតមិនទាន់បានបញ្ជាក់នៅឡើយអំពីលក្ខណៈនៃការខ្វែងយោបល់គ្នារបស់ពួកគាត់ ដូចដែលមេធាវីការពារក្តីបានស្នើសុំរួចមកហើយនោះ។ ហេតុដូច្នេះ សិទ្ធិជាសារវ័ន្តរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការដែលបង្កើតដោយច្បាប់ សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងសិទ្ធិក្នុងការទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី កំពុងរងការរំលោភបំពាន។ មេធាវីការពារក្តីចង់បាននូវការបញ្ជាក់ថា ដីកាកោះត្រូវបានចេញដោយអនុលោមតាមក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់អ្នកស្រី អ៊ឹម ចែម។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំព្យួរដីកាកោះហៅអ្នកស្រី អ៊ឹម ចែម និងដីកាកោះហៅសហមេធាវីការពារក្តីគាត់ រហូតទាល់តែសហចៅក្រមស៊ើបអង្កេត ក) ស្នើទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពដីកាកោះ និង ខ) គួសបញ្ជាក់អំពីលក្ខណៈនៃការខ្វែងយោបល់គ្នារបស់ពួកគាត់។ សំណើនេះត្រូវបានដាក់ជាភាសាអង់គ្លេស ហើយឯកសារបកប្រែជាភាសាខ្មែរ នឹងត្រូវដាក់ជូនតាមក្រោយទៀត ដោយសារតែអង្គភាពបកប្រែភាសា មិនអាចបកប្រែឯកសារនេះឱ្យបានទាន់ពេលវេលា។

## I. សាវតារ

1. កាលពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណើសុំការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង[1] ដែលសំណើនេះ មិនទាន់មានការសម្រេចនៅឡើយទេ[2]។

---

[1] ឯកសារ D201 *សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤។

2. កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្ដី បានដាក់លិខិតមួយច្បាប់ដែលស្នើសុំឱ្យបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងការទំនាក់ទំនងទាំងអស់ជាផ្លូវការ ទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម ត្រូវបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ[3]។

3. កាលពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបថា "ទាក់ទងនឹងការខ្វែងយោបល់គ្នាដែលមានយោងនៅក្នុងលិខិតរបស់លោក [មេធាវីការពារក្ដី] រយៈពេល ៣០ ថ្ងៃ ដែលមានចែងនៅក្នុងអនុវិធាន ៧២(៣) [នៃវិធានផ្ទៃក្នុង] បានកន្លងផុតហើយ ដោយគ្មានការបញ្ជូនការខ្វែងយោបល់ណាមួយទៅ [អង្គបុរេជំនុំជម្រះ]នោះទេ"[4]។ ចាប់តាំងពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ ការទំនាក់ទំនងទាំងអស់ជាមួយមេធាវីការពារក្ដី ត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯងប៉ុណ្ណោះ។

4. កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានជូនដំណឹងមេធាវីការពារក្ដីថា ការបង្ហាញខ្លួនលើកដំបូងរបស់អ្នកស្រី អ៊ឹម ចែម ត្រូវបានកំណត់កាល

---

[2] មេធាវីការពារក្ដីកត់សម្គាល់ឃើញថា ខ្លួនទទួលបានតែការឆ្លើយតបតែមួយគាត់ដែលថា "សហចៅក្រមស៊ើបអង្កេតបានដាក់សំណើចូលក្នុងសំណុំរឿង ហើយនឹងឆ្លើយតបទៅនឹងសំណើនេះក្នុងរយៈពេលសមស្រប"។ *សូមមើល* ឯកសារ D201/1 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឆ្លើយតបទៅនឹង *សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។ មេធាវីការពារក្ដីក៏បានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើសុំដោយប្រយោល ដោយមិនមានសំអាងហេតុតាមផ្លូវច្បាប់ តាមរយៈការលើកឡើងថា មេធាវីការពារក្ដី "នឹងត្រូវបាន ផ្ដល់សិទ្ធិចូលមើលសំណុំរឿង បន្ទាប់ពីការចូលបង្ហាញខ្លួនលើកដំបូង" *សូមមើល* ឯកសារ A151/1/1 លិខិតរបស់សហ ចៅក្រមស៊ើបអង្កេត Harmon ផ្ញើជូនមេធាវីការពារក្ដី (មិនមានកម្មវត្ថុ) ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[3] ឯកសារ A122 សំណើសុំឱ្យបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការ ទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

[4] ឯកសារ A122/1 *លិខិតរបស់លោកស្នើសុំឱ្យបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបទៅក្នុងការទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

បរិច្ឆេទថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ និងបានជូនដំណឹងដល់មេធាវីការពារក្តីថា ដីកាកោះរបស់អ្នកស្រី អ៊ឹម ចែម នឹងត្រូវប្រគល់ជូនដល់អ្នកស្រីដោយផ្ទាល់ ឬជូនទៅមេធាវីតំណាងអ្នកស្រី អ៊ឹម ចែម ប្រសិនបើមានការអនុញ្ញាតពីអ្នកស្រី[5]។

5. កាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតទាំងពីររូបថា ដីកាកោះនឹងត្រូវតែប្រគល់ជូនអ្នកស្រី អ៊ឹម ចែម ដោយផ្ទាល់។ សហមេធាវីការពារក្តីក៏បានស្នើសុំឱ្យចម្លងដីកាកោះអ្នកស្រី អ៊ឹម ចែម មួយច្បាប់ ដល់សហមេធាវីការពារក្តីផងដែរ[6]។

6. កាលពីថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតគួសបញ្ជាក់អំពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម[7]។ សហមេធាវីការពារក្តីមិនទាន់បានទទួលការឆ្លើយតបណាមួយឡើយរហូតមកទល់ពេលនេះ[8]។

---

[5] ឯកសារ A122/2 *ការរៀបចំបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤។ កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តីសុំឱ្យបន្ថែមពេលវេលាក្នុងការឆ្លើយតបទៅនឹងលិខិតរបស់លោកចៅក្រម ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤។ *សូមមើល* ឯកសារ A122/4 *ការរៀបចំបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ* ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៤ ជាការឆ្លើយតបទៅនឹងឯកសារ A122/3 *សំណើសុំពេលវេលាបន្ថែមក្នុងការឆ្លើយតបទៅនឹងលិខិតរបស់លោកចៅក្រម ទាក់ទងនឹងការរៀបចំចូលបង្ហាញខ្លួនលើកដំបូងរបស់អ្នកស្រី អ៊ឹម ចែម* ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៤។

[6] ឯកសារ A122/5 *ទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤។

[7] ឯកសារ D204 *ញត្តិរបស់ អ៊ឹម ចែម ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្រាយបំភ្លឺពាក់ព័ន្ធនឹង៖ ក. ការយល់របស់សហចៅក្រមស៊ើបអង្កេតទៅលើវិធាន ៧២ នៃវិធានផ្ទៃក្នុង ខ. លក្ខណៈនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត គ. កាលបរិច្ឆេទនៃការកើតមានការខ្វែងយោបល់គ្នា និង ឃ. ហេតុផលរបស់សហចៅក្រមស៊ើបអង្កេតចំពោះការខ្វែងយោបល់គ្នានោះ។

[8] ការឆ្លើយតបតែមួយគត់ដែលមេធាវីការពារក្តីទទួលបានគឺថា សំណើសុំ "ត្រូវបានដាក់នៅក្នុងសំណុំរឿង ហើយនឹងត្រូវឆ្លើយតបក្នុងពេលសមស្រប"។ *សូមមើល* ឯកសារ D204/1 *ការឆ្លើយតបរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត* សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ

7. កាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចេញដីកាកោះហៅអ្នកស្រី អ៊ឹម ចែម ឱ្យមកបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤[9]។ នៅថ្ងៃជាមួយគ្នានេះ លោកចៅក្រមស៊ើបង្កេត ក៏បានចេញដីកាកោះមេធាវីឱ្យមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងរបស់កូនក្តីខ្លួន[10]។

8. កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់លិខិតចំនួនបីជូនទៅសហចៅក្រមស៊ើបអង្កេត។ លិខិតមួយ លើកឡើងថា មេធាវីការពារក្តីមិនចាត់ទុកដីកាកោះហៅកូនក្តីនេះ ថាជាដីកាមានសុពលភាពនោះទេ[11]។ លិខិតមួយទៀត គឺជាការស្នើសុំឱ្យចូលមើលសំណុំរឿង មុនពេលអ្នកស្រី អ៊ឹម ចែម ចូលបង្ហាញខ្លួនជាលើកដំបូងតាមការស្នើឡើង[12] និងលិខិតមួយទៀត លើកឡើងសាជាថ្មីអំពីសំណើសុំសំណៅថតចម្លងនូវដីកាកោះហៅអ្នកស្រី អ៊ឹម ចែម មួយច្បាប់[13]។

---

*ទៅនឹងសំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។

[9] ឯកសារ A150 *ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤។

[10] ឯកសារ A151 *ដីកាកោះមេធាវី* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤។ សហមេធាវីការពារក្តី យល់ឃើញថា ដីកាកោះនេះគឺគ្រាន់តែមានលក្ខណៈជាសំណើសុំមួយប៉ុណ្ណោះ ដោយផ្អែកលើពាក្យពេចន៍ក្នុងដីកាកោះនេះ។ លើសពីនេះទៀត សហមេធាវីអន្តរជាតិកំពុងស្ថិតក្នុងពេលវិស្សមកាលជាមួយក្រុមគ្រួសារមួយរយៈពេលយូរនៅអឺរ៉ុបកាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ ហេតុដូច្នេះមិនអាចមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងកាលពីថ្ងៃនោះបានទេ។

[11] ឯកសារ A151/2 *ការឆ្លើយតបទៅនឹងដីកាកោះឱ្យអ្នកស្រី អ៊ឹម ចែម ចូលបង្ហាញខ្លួនជាលើកដំបូង កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ នៅពេលដែលមេធាវីការពារក្តីលើកឡើងសាជាថ្មីថា រហូតដល់ ឬលុះត្រាតែសហចៅក្រមស៊ើបអង្កេតឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីសុំឱ្យធ្វើការស្រាយបំភ្លឺទៅនឹងការខ្វែងគំនិតគ្នារបស់សហចៅក្រមស៊ើបអង្កេត (D204) បើមិនដូច្នេះទេ មេធាវីការពារក្តីមិនចាត់ទុកថា ដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែមួយរូបនោះ ជាដីកាកោះមានសុពលភាពនោះទេ។ ហេតុដូច្នេះ មេធាវីការពារក្តីបដិសេធការអញ្ជើញឱ្យចូលរួមនៅក្នុងការការបង្ហាញខ្លួនជាលើកដំបូងរបស់អ្នកស្រី អ៊ឹម ចែម ដែលបានស្នើឡើងនោះ។

[12] ឯកសារ A151/2 *លិខិតស្នើសុំពិនិត្យមើលសំណុំរឿងមុនពេលការស្នើសុំឱ្យអ្នកស្រី អ៊ឹម ចែម បង្ហាញខ្លួនជាលើកដំបូង និងស្នើសុំឱ្យប្តូរកាលបរិច្ឆេទការបង្ហាញខ្លួនលើកដំបូងរបស់អ្នកស្រីទៅពេលក្រោយ* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[13] ឯកសារ A151/3 *សំណើសុំឯកសារថតចម្លងដីការបស់អ្នកស្រី អ៊ឹម ចែម ឱ្យបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ឯកសារថតចម្លងដីកាកោះហៅអ្នកស្រី អ៊ឹម

សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ

9. កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់លិខិតចំនួនពីរ៖ លិខិតទីមួយ លើកទឡ្ហីករណ៍ថា ចៅក្រមស៊ើបអង្កេតតែមួយរូបអាចចេញដីកាកោះតែឯកឯងបាន[14] និងលិខិតមួយទៀត បដិសេធសំណើរបស់មេធាវីការពារក្ដីដែលស្នើសុំពិនិត្យមើលសំណុំរឿងមុនពេលអ្នកស្រី អ៊ឹម ចែម ចូលបង្ហាញខ្លួនជាលើកដំបូងតាមការស្នើសុំ[15]។

## II. ភាពអាចទទួលយកបាន

10. សំណើនេះអាចទទួលយកបានអនុលោមតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង ដែលបានចែងថា "កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង ចែងអំពីសិទ្ធិនានារបស់ជនសង្ស័យនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក។ ដូច្នេះ វិធាន ២១(១) នៃវិធានផ្ទៃក្នុង តម្រូវថា "វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់<u>ប្រយោជន៍របស់ជនសង្ស័យ</u> ជនត្រូវចោទ... <u>ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព</u>"[16]។ យោងតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង បញ្ហានានាដែលបានលើកឡើងនៅក្នុងសំណើនេះ ពាក់ព័ន្ធនឹងភាពយុត្តិធម៌ជាសារវ័ន្តនៃកិច្ចដំណើរការនីតិវិធីលើរូបអ្នកស្រី អ៊ឹម ចែម។

---

ចែម ត្រូវបានទទួលនៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។ *សូមមើល* ឯកសារ A122/6.1 ឯកសារថតចម្លង*ដីកាកោះឲ្យបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[14] ឯកសារ A122/6 *ការឆ្លើយតបទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូន អ៊ឹម ចែម* របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ *ដែលភ្ជាប់* ឯកសារ A122/6.1 *ឯកសារថតចម្លងដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[15] ឯកសារ A151/1/1 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូនមេធាវីការពារក្ដី (មិនមានកម្មវត្ថុ) ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[16] គូសបញ្ជាក់បន្ថែម។

## III. ច្បាប់ជាធរមាន

11. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

12. មាត្រា ១២(២) នៃកិច្ចព្រមព្រៀង ក៏បានចែងថាថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។

13. មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ"។

14. វិធាន ៧៣ នៃវិធានផ្ទៃក្នុង ចែងថា៖ "មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ចដើម្បីពិនិត្យលើ៖ [...] ខ-ពាក្យសុំមោឃភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦"។

15. វិធាន ៧៦(២) ចែងថា៖ "ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់ពីមូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួល

យក ឬ បដិសេធសំណើសុំភ្លាមៗ តាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះគឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ"។

16. វិធាន ៤៨ ចែងថា៖ "កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។

17. វិធាន ២១(១) ចែងថា៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ... ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព [...]"។

18. មាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ដែលប្រទេសកម្ពុជាគឺជាហត្ថលេខីមួយ កតិកាសញ្ញានេះចែងអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ជាពិសេស មាត្រា ១៤(១) នៃកតិកាសញ្ញា ICCPR ចែងថា៖ "... ជនគ្រប់រូប ត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។

## IV. ឧត្តរករណ៍

19. សិទ្ធិជាសារវ័ន្តរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានការជំនុំជម្រះដោយសាលាក្តីដែលបង្កើតឡើងដោយច្បាប់ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ[17] កិច្ចព្រមព្រៀង[18] ច្បាប់ស្តីពីការបង្កើត

[17] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឲ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ

អ.វ.ត.ក[19] និង ICCPR[20]។ អ្នកស្រី អ៊ឹម ចែម ក៏មានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ផ្អែកតាមវិធានផ្ទៃក្នុង[21]។ អ្នកស្រីមានសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon តែម្នាក់ឯងនោះ បានរារាំងអ្នកស្រីមិនឲ្យទទួលបានសិទ្ធិដែលបានលើកឡើងខាងលើនេះ ហេតុដូច្នេះ ទង្វើនេះ ជាការរំលោភបំពានទៅលើសិទ្ធិរបស់គាត់។

20. សហមេធាវីការពារក្ដីលើកឡើងថា ការមោឃភាពដីកាកោះហៅអ្នកស្រី អ៊ឹម ចែម និងដីកាកោះសហមេធាវីការពារក្ដី ត្រូវតែទទួលបានការអនុញ្ញាត ដោយអនុលោមតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង។ ការអនុញ្ញាតនេះ គឺដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាកោះតែម្នាក់ឯងតែប៉ុណ្ណោះ។ លើសពីនេះទៀត នៅក្នុងកាលៈទេសៈដែលលក្ខណៈនៃការខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេតជាតិ មិនត្រូវបានគូសបញ្ជាក់តាមសំណើសុំរបស់មេធាវីការពារក្ដី និងនៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានបំណងចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ប៉ុន្តែ បែជាមិនបានផ្ដល់ឱកាសដឹងឮដល់អ្នកស្រី ដែលទង្វើបែបនេះ គឺជាករណីមិនគោរពវិធានបញ្ញត្តិ ដែលពិតជាធ្វើឲ្យប៉ះពាល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងមូលនៅក្នុងរឿងក្ដីទាក់ទងនឹងអ្នកស្រី អ៊ឹម ចែម ព្រមទាំងប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និង

---

អនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។ មាត្រា ១៤ នៃកតិកាសញ្ញា ICCPR ដែលប្រទេសកម្ពុជាជារដ្ឋហត្ថលេខីនោះ ចែងអំពីសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលក្នុងនោះរួមមានសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្ដីដែលបង្កើតឡើងដោយច្បាប់។ *សូមមើល* កតិកាសញ្ញា ICCPR មាត្រា ១៤(១)។

[18] មាត្រា ១២(២) នៃកិច្ចព្រមព្រៀង ចែងអំពី៖ “អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ”។

[19] មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា៖ “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ”។

[20] កតិកាសញ្ញា ICCPR មាត្រា ១៤(១)។

[21] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។ នៅក្នុង *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព*[22] អង្គបុរេជំនុំជម្រះបានសម្រេចថា "ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា ICCPR អាចបញ្ជាក់បានគ្រប់គ្រាន់ពីកំហុសផ្នែកនីតិវិធី ហើយដែលនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចការនានារបស់តុលាការអាចចាត់ទុកថា មោឃៈ"[23]។ ដោយសារមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញា ICCPR ត្រូវបានលើកឡើងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[24] ដែលចែងថា ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ"[25] ហេតុដូច្នេះ យើងអាចនិយាយដោយចំពោះបានថា ការរំលោភបំពានលើសិទ្ធិរបស់ជនសង្ស័យ អាចចាត់ទុកជាករណីមិនគោរពវិធានបញ្ញត្តិផងដែរ។

21. មេធាវីការពារក្តីលើកឡើងថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម គឺជាករណីមិនគោរពវិធានបញ្ញត្តិ ពីព្រោះតែ៖ ក) ដីកាកោះដែលចេញដោយចៅក្រមស៊ើបអង្កេតតែមួយរូប មិនចងកាតព្វកិច្ចផ្លូវច្បាប់នោះទេ។ ខ) ដំណើរការនីតិវិធីនៃការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម រួមបញ្ចូលនូវសិទ្ធិរបស់អ្នកស្រីក្នុងការធ្វើសម្ភាសន៍ និងការចូល

[22] ឯកសារ D55/I/8 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ("សាលដីកា អ.ប.ជ លើពាក្យសុំមោឃភាព")។

[23] សាលដីកាអ.ប.ជ លើពាក្យសុំមោឃភាព កថាខណ្ឌ៤០។ *សូមមើលផងដែរ* ឯកសារ D263/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (*D263/1*)* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១៨ ដែលអង្គបុរេជំនុំជម្រះបានសម្រេចថា នៅពេល "ពិចារណាទៅលើពាក្យសុំនៅក្រោមវិធាន៧៦(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវតែជឿជាក់ថា មានពាក្យសុំដែលគាំទ្រដោយទឡ្ហីករណ៍ប្រកបដោយហេតុផល ដោយការបញ្ជាក់អះអាងថា មានកំហុសនីតិវិធី ហើយកំហុសបែបនេះ វារំលោភសិទ្ធិរបស់ភាគីដាក់ពាក្យសុំ"។

[24] *សូមមើល* ឯកសារ D264/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (*D264/1*)* ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ១៣។

[25] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

ពិនិត្យមើលសំណុំរឿង និង គ) មិនទាន់មានការផ្តល់នូវការគូសបញ្ជាក់អំពីលក្ខណៈនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនោះទេ។

22. **ចំណុចទីមួយ៖** មេធាវីការពារក្តីបញ្ជាក់ឡើងវិញអំពីសារណារបស់ខ្លួនពីមុនៗថា ដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែមួយរូប មិនចងកាតព្វកិច្ចផ្លូវច្បាប់នោះទេ[26]។ នៅក្នុងសារណាពីមុនៗរបស់ខ្លួន មេធាវីការពារក្តីរម្លឹកថា សហចៅក្រមស៊ើបអង្កេតត្រូវបានបង្កើតឡើងក្នុងគោលបំណងឱ្យធ្វើការសហការគ្នានៅក្នុងគ្រប់កិច្ចការស៊ើបអង្កេតទាំងអស់[27] ដែលជាការទទួលខុសត្រូវរួមគ្នារបស់ពួកគាត់[28]។ នៅក្នុង*សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន ស្តីពីសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត*[29] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានទទួលស្គាល់លក្ខខណ្ឌតម្រូវដែលថា ការចោទប្រកាន់គឺជាបុព្វសិទ្ធិមួយរបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប។ តាមពិតទៅ នៅពេលសង្ខេបលក្ខខណ្ឌតម្រូវជាសំខាន់ និងផ្លូវការសម្រាប់ធ្វើការចោទប្រកាន់លើជនសង្ស័យក្នុងអំឡុងពេលស៊ើបអង្កេត[30] សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ថា "ការសម្រេចធ្វើការចោទប្រកាន់ គឺជាបុព្វសិទ្ធិមួយរបស់ ស.ច.ស"[31] ដោយប្រើប្រាស់ពហុវចនៈ មិនមែនឯកវចនៈនោះទេ។ ការសម្រេចបែបនេះមានភាពស្របជាមួយនឹងបទប្បញ្ញត្តិគតិយុត្តិ អ.វ.ត.ក ទាក់ទងនឹងការសហការគ្នារវាងសហចៅក្រមស៊ើប

---

[26] *សូមមើល* ឯកសារ A122/5 *ទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារ D204 *ញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យមានការស្រាយបំភ្លឺ ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើប អង្កេត* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារ A151/2 *ការឆ្លើយតបទៅនឹងដីកាកោះឱ្យអ្នកស្រី អ៊ឹម ចែម ចូលបង្ហាញខ្លួនជាលើកដំបូង កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[27] មាត្រា ៥ (៤) នៃកិច្ចព្រមព្រៀងចែងថា៖ "សហចៅក្រមស៊ើបអង្កេត<u>ត្រូវសហការគ្នា</u> ដើម្បីឈានទៅដល់<u>ការឯកភាពគ្នាមួយ</u>ក្នុងការស៊ើបអង្កេត"។ (គូសបញ្ជាក់បន្ថែម)

[28] មាត្រា ២៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ *សូមមើលផងដែរ* មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។

[29] ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់ ក.ស.ច.ស លើសំណើសុំចូលពិនិត្យមើលសំណុំរឿង")។

[30] សេចក្តីសម្រេចរបស់ ក.ស.ច.ស លើសំណើសុំចូលពិនិត្យមើលសំណុំរឿង កថាខណ្ឌ ៤០-៤៤។

[31] សេចក្តីសម្រេចរបស់ ក.ស.ច.ស លើសំណើសុំចូលពិនិត្យមើលសំណុំរឿង កថាខណ្ឌ ៤០។

អង្កេតទាំងពីររូប[32] ហើយដែលប្រការនេះ ត្រូវបានមេធាវីការពារក្ដីរម្លឹកជាប្រចាំ។ បើគ្មានការសហការណាមួយរវាងសហចៅក្រមស៊ើបអង្កេត នៅពេលដែលសហចៅក្រមស៊ើបអង្កេតគឺជាផ្នែកនៃប្រព័ន្ធគតិយុត្តិដែលនៅគ្រប់កម្រិតទាំងអស់ តម្រូវឱ្យមានកិច្ចសហការគ្នារវាងសហ-ចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហភាគកម្ពុជា[33] យើងអាចនិយាយបានថា អ្នកស្រី អ៊ឹម ចែម មិនត្រូវបានទទួលរងនូវការស៊ើបអង្កេត ឬនឹងត្រូវបានចោទប្រកាន់ ដោយតុលាការដែលត្រូវបង្កើតឡើងដោយច្បាប់នោះទេ។ ការដែលអ្នកស្រី អ៊ឹម ចែម ត្រូវឆ្លងកាត់ដំណាក់កាលសំខាន់នៃកិច្ចដំណើរការនីតិវិធីផ្សេងៗក្នុងការការចោទប្រកាន់ ដោយអ្នកស្រីជួបប្រទះនូវទិដ្ឋភាពចាំបាច់ទាំងអស់ដើម្បីធានានូវការប្រព្រឹត្តិទៅនៃកិច្ចដំណើរនីតិវិធីព្រហ្មទណ្ឌដែលមាន ព្រមទាំងការជាប់ជំពាក់ទាក់ទងដ៏ធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់មកលើអ្នកស្រី នៅពេលដែលមានតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបំពេញកិច្ចតែម្នាក់ឯងនោះ វាគឺជាការចំអកទៅលើទស្សនទាន ដែលថា អ.វ.ត.ក គឺជាផ្នែកនៃប្រព័ន្ធគតិយុត្តិកម្ពុជា។ សេចក្ដីសម្រេចសំខាន់ៗទាក់ទិននឹង អ.វ.ត.ក រួមទាំងសេចក្ដីសម្រេចចោទប្រកាន់លើបុគ្គលណាមួយនោះ អាចធ្វើទៅបាន និងត្រូវតែជាសេចក្ដីសម្រេចមួយដែលខាងភាគីកម្ពុជាដើរតួនាទីខ្ពស់ បើមិនអញ្ចឹងទេ អ.វ.ត.ក នឹងបាត់បង់នូវអំណះអំណាងដែលអះអាងថាជា អង្គជំនុំជម្រះ *នៅក្នុងតុលាការកម្ពុជា*។

---

[32] *សូមមើល* មាត្រា ១ នៃកិច្ចព្រមព្រៀងដែលចែងថា៖ “គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ [...] ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះ ផ្ដល់មូលដ្ឋានគតិយុត្តិ គោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ”។ មាត្រា ៥(១) នៃកិច្ចព្រមព្រៀងដែលចែងថា៖ “មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត”។ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងដែលចែងថា៖ “សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត”។ មាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលចែងថា៖ “រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាខ្មែរ និងម្នាក់ទៀតជាបរទេស”។ វិធាន ១៤(៤) នៃវិធានផ្ទៃក្នុង ចែងថា៖ “វៀរលែងតែសកម្មភាពណា ដែលតម្រូវឱ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចទៅឱ្យសហចៅក្រមស៊ើបអង្កេត ណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន។ វិធាន ៧២(៣) ដែលចែងថា “ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា”។

[33] *សូមមើល* មាត្រា ១ នៃកិច្ចព្រមព្រៀង។

23. សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើកទឡ្ហីករណ៍ថា កិច្ចស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតតែមួយរូប មានសុពលភាពផ្លូវច្បាប់ ដោយមិនមានកម្រិតកំណត់អ្វីទាំងអស់ ផ្អែកលើ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ*[34]។ ទោះបីជាយ៉ាងណាក៏ដោយ ជាក់ស្តែងនៃសេចក្តីសម្រេចនេះ មិនបាន ឬ មិនអាចគាំទ្រដល់ការលើកឡើងថា ដីកាកោះដែលចេញទៅឱ្យជនសង្ស័យម្នាក់ ក្នុងគោលបំណងចោទប្រកាន់គាត់ ជាមួយនឹងការចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែមួយរូប មានសុពលភាពផ្លូវច្បាប់ និងចំណងកាតព្វកិច្ច ទោះក្រោមកាលៈទេសៈណាក៏ដោយ។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា សេចក្តីសម្រេចដែលសហចៅក្រមស៊ើបអង្កេតប្រើជាសំអាងនោះ ទាក់ទងនឹង<u>កិច្ចស៊ើបសួរ</u>ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯង។ ហើយករណីនេះមិនមានការតវ៉ាទេ ដោយអង្គបុរេជំនុំជម្រះបានរម្លឹកថា "ក្នុងករណីមានសំណើសុំបើកកិច្ចស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត និងមានបណ្តឹងឧទ្ធរណ៍មកអង្គបុរេជំនុំជម្រះនោះ រាល់ការចាត់វិធានការ ឬការទទួលយកសំណើសុំដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតតែមួយរូប នឹងត្រូវតម្កល់"[35]។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចចោទប្រកាន់លើជនសង្ស័យណាម្នាក់ មិនមែនជាកិច្ចស៊ើបសួរនោះទេ[36] ហេតុដូច្នេះ វាមិនអាចធ្វើឡើងដោយចៅក្រមស៊ើបអង្កេតតែមួយរូបបានឡើយ។ អាស្រ័យហេតុនេះ ដីកាកោះ ដែលចេញក្នុងគោលបំណងចោទប្រកាន់ជនសង្ស័យ មិនអាចចាត់ទុកជាកិច្ចស៊ើបសួរនោះទេ។

---

[34] ឯកសារ A122/6 *ការឆ្លើយតបទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម* របស់សហចៅក្រមស៊ើប អង្កេតអន្តរជាតិ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ *ដោយយោងទៅលើ* ឯកសារ D427/1/30 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ("សាលដីកាអ.ប.ជ លើដីកាដំណោះស្រាយ") កថាខណ្ឌ ២៧២-២៧។

[35] សាលដីកា អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ២៧៥។

[36] *សូមមើល* វិធាន ៥៥(៥) ដែលចែងថា "សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត" និងផ្តល់នូវបញ្ជីនៃកិច្ចស៊ើបសួរមួយ ដែលមិនបញ្ចូលការសម្រេចក្នុងការចោទប្រកាន់ជនសង្ស័យ។

24. លើសពីនេះទៀត នៅក្នុង*សាលដីកាជាសាធារណៈលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយកមកធ្វើជាមូលដ្ឋានសំអាងនោះ អង្គបុរេជំនុំជម្រះបានលើកឡើងថា សហចៅក្រមស៊ើបអង្កេត នៅពេលដោះស្រាយលើបញ្ហានៃការជំនុំជម្រះសម្រាប់ឧក្រិដ្ឋកម្មកម្រិតជាតិ បានសម្រេចតាមការព្រមព្រៀងគ្នាទៅវិញទៅ មកក្នុងការបញ្ជូនជនជាប់ចោទនៃសំណុំរឿង ០០២ ទៅជំនុំជម្រះ[37]។ នៅក្នុងរឿងក្តីរបស់អ្នកស្រី អ៊ឹម ចែម មិនត្រឹមតែមិនមានសេចក្តីសម្រេចទៅលើករណីថាតើសហចៅក្រមស៊ើបអង្កេតតែម្នាក់អាចកោះហៅគាត់តាមផ្លូវច្បាប់ដើម្បីមកធ្វើការចោទប្រកាន់បាន ឬយ៉ាងណានោះទេ ក្រៅពីការខ្វែងយោបល់គ្នាជាមួយនឹងសហចៅក្រមស៊ើបអង្កេតជាតិ ប៉ុន្តែការសម្រេចកោះហៅអ្នកស្រី អ៊ឹម ចែម ដើម្បីយកមកធ្វើការចោទប្រកាន់នោះទៀតសោត ក៏ពុំបានកើតចេញពីការព្រមព្រៀងគ្នាទៅវិញទៅមករវាងសហចៅក្រមស៊ើបអង្កេតដែរ[38]។ ផ្ទុយទៅវិញអ្នកស្រី អ៊ឹម ចែម កំពុងត្រូវបានស៊ើបអង្កេតដោយភាគីអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេតតែម្ខាងប៉ុណ្ណោះ ហើយដែលប្រការនេះ គេអាចសន្និដ្ឋានបានថា សហចៅក្រមស៊ើបអង្កេតជាតិ ពុំយល់ស្របឲ្យមានចោទប្រកាន់លើអ្នកស្រីឡើយ។ ប្រសិនបើការសន្និដ្ឋាននេះពុំត្រឹមត្រូវទេនោះ សហចៅក្រមស៊ើបអង្កេតទាំងពីរប្រាកដជានឹងកែតម្រូវនូវការយល់ឃើញនេះភ្លាមៗបាត់ទៅហើយ។

---

[37] សាលដីការបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ២៧២-២៧៤។ *សូមមើលផងដែរ* សាលដីការបស់ អ.ប.ជ ដែលអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនត្រឹមតែបានសម្រេចតាមការព្រមព្រៀងគ្នាទៅវិញទៅមកយល់ព្រមតាមសំណើសុំនោះទេ សហចៅក្រមស៊ើបអង្កេតក៏បានយល់ព្រមលើសេចក្តីសន្និដ្ឋានបញ្ជូនជនជាប់ចោទទៅជំនុំជម្រះសម្រាប់ឧក្រិដ្ឋកម្មជាតិដែរ។

[38] ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានទាំងអស់ពាក់ព័ន្ធនឹងដីកាកោះ និងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់គត់ នេះមានន័យថា ពុំមាន “ការព្រមព្រៀងគ្នាទៅវិញទៅមក” រវាងសហចៅក្រមស៊ើបអង្កេត។ *សូមមើល* ឯកសារ A122/2 *ការរៀបចំបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៤។ ឯកសារ A122/4 *ការរៀបចំបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ* ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារ A150 *ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង* ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៤។ ឯកសារ A151 *ដីកាកោះមេធាវី* ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៤។ ឯកសារ A122/6 *ការឆ្លើយតប*របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ *ទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ្នកស្រី អ៊ឹម ចែម* ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។ ឯកសារ A151/1/1 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ផ្ញើជូនក្រុមមេធាវីការពារក្តី (គ្មានកម្មវត្ថុ) ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។

25. **ចំណុចទីពីរ** ក្រុមមេធាវីការពារក្ដីសន្និដ្ឋានថា ដំណើរការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម រួមបញ្ចូលនូវ សិទ្ធិរបស់គាត់ក្នុងការធ្វើបទសម្ភាសន៍ និងមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើងថា ការកោះហៅអ្នកស្រី អ៊ឹម ចែម ឲ្យមកបង្ហាញខ្លួនជាលើកដំបូងតាមកាលកាលបរិច្ឆេទកំណត់នោះ ពុំមានគោលបំណងសម្ភាសន៍គាត់នោះទេ ប៉ុន្តែ ក្នុងគោលបំណងដើម្បីកត់ត្រាអត្តសញ្ញាណគាត់ ជូនដំណឹងគាត់អំពីបទចោទ និងដើម្បីជម្រាបគាត់អំពីសិទ្ធិមានមេធាវី និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប[39]។ ខណៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានទទួលស្គាល់កាលពីពេលមុនថា បើទោះជាយុត្តិសាស្ត្រប្រទេសបារាំង "ពុំអាចអនុវត្ត ឬចងកាតព្វកិច្ចដោយផ្ទាល់ តែថា [យុត្តិសាស្ត្រ] នេះអាចផ្ដល់ជាគោលការណ៍ណែនាំដ៏មានប្រយោជន៍សម្រាប់ការបកស្រាយវិធានផ្ទៃក្នុង"[40] ដែលយុត្តិសាស្ត្រនេះ មិនត្រូវបានយកមកពិចារណាទេក្នុងពេល ដោយពុំបានផ្ដល់ហេតុផលណាមួយឡើយ។ តាមច្បាប់បារាំង ចំណុចសំខាន់នៃការបង្ហាញខ្លួនលើកដំបូង គឺការសួរចម្លើយជនសង្ស័យនៅមុនពេលចោទប្រកាន់ជននេះជាផ្លូវការ[41]។ មេធាវីរបស់ជនសង្ស័យត្រូវតែទទួលបាននូវការកោះហៅឲ្យបានប្រាំថ្ងៃមុនពេលសួរចម្លើយបុគ្គលដែលខ្លួនជួយការពារ[42] និងត្រូវទទួលបានឱកាសពិនិត្យមើលសំណុំរឿង ក្នុងរយៈពេលបួនថ្ងៃមុនពេលសួរចម្លើយនោះ[43]។ ប្រសិនបើមិនមានការគោរពតាមពេលវេលាកំណត់នេះទេ ចៅក្រមស៊ើប

---

[39] ឯកសារ A151/1/1 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ផ្ញើជូនក្រុមមេធាវីការពារក្ដី (គ្មានកម្មវត្ថុ) ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។

[40] សេចក្ដីសម្រេចរបស់ ស.ច.ស.អ លើសំណើសុំចូលមើលសំណុំរឿង កថាខណ្ឌ ៥៥។

[41] *សូមមើល* មាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលចែងថា ចៅក្រមស៊ើបអង្កេតអាចបន្តនីតិវិធីចោទប្រកាន់ជនសង្ស័យបាន<u>បន្ទាប់ពី</u>បានកត់ត្រាចម្លើយរបស់ជនសង្ស័យរួច ឬ <u>បន្ទាប់ពី</u>បានសួរចម្លើយជនសង្ស័យរួចរាល់។ *សូមមើល* បទប្បញ្ញត្តិស្រដៀងគ្នា មាត្រា ៨០-២ នៃក្រមដដែលនេះ។ ក្រៅពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងច្បាស់ថា ការចោទប្រកាន់អាចធ្វើទៅបានក្រោយពេលជនសង្ស័យបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។ *សូមមើល* មាត្រា ៨០-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១៤ al. ២។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១៤ al. ៣។

អង្គេតមិនអាចបន្តនីតិវិធីសួរចម្លើយឡើយ[44]។ ព្រោះហេតុនេះ និងដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានទទួលស្គាល់រួចមកហើយ នូវគោលការណ៍ណែនាំស្តីពីការបកស្រាយវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងការចោទប្រកាន់ជនសង្ស័យ គួរតែត្រូវយកចេញពីច្បាប់បារាំង។ ដូច្នេះ អ្នកស្រី អ៊ឹម ចែម ត្រូវតែបាន ផ្តល់នូវបទសម្ភាសន៍ ក្នុងពេលបង្ហាញខ្លួនលើកដំបូង នៅមុនពេលចោទប្រកាន់មកលើរូបអ្នកស្រី ហើយក្រុមមេធាវីការពារក្តីត្រូវទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿងនៅមុនពេលសួរយកចម្លើយពីកូនក្តីរបស់ពួកគាត់។ នេះក៏ជាផ្នែកមួយនៃសិទ្ធិជាសារវ័ន្តរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានការដឹងឮ។ ម្យ៉ាងវិញទៀត ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយមិនបានស្តាប់រឿងរ៉ាវរបស់អ្នកស្រីនោះ នោះវាជាការបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចចិត្តរួចទៅហើយពីលទ្ធភាពនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ទៅលើឧក្រិដ្ឋកម្មមួយចំនួន ហើយលោកចៅក្រមក៏អាចនឹងជឿជាក់ថា *អ្វីក៏ដោយដែលអ្នកស្រី អ៊ឹម ចែម និយាយ* អាចនឹងមានឥទ្ធិពលលើគំនិតរបស់លោកចៅក្រមបានទេចំពោះបញ្ហានេះ។ មានន័យថា សហ-ចៅក្រមស៊ើបអង្កេតអន្តរជាតិ មានបុរេវិនិច្ឆ័យទៅលើលទ្ធភាពនៃការទទួលខុសត្រូវរបស់អ្នកស្រីហើយដែលទង្វើនេះ មិនមានទស្សនៈបើកទូលាយឡើយអំពីខ្លឹមសារនៃលទ្ធភាពក្នុងការទទួលខុសត្រូវ។ ការពិចារណាទាំងនេះធ្វើឲ្យកាន់តែមានការព្រួយបារម្ភឡើងចំពោះថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបំពេញកិច្ចតែម្នាក់ឯង នៅខណៈពេលដែលខ្លួនកំពុងតែមានការខ្វែងយោបល់គ្នាជាមួយនឹងសហភាតាជាតិរបស់គាត់នោះ។

26. អាស្រ័យហេតុនេះ ការចេញដីកាកោះអ្នកស្រី អ៊ឹម ចែម ឲ្យមកបង្ហាញខ្លួនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទំនងជាការធ្វើឡើងដោយ *ហួសដែនអំណាច (ultra vires)* ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានសម្រេចចោទប្រកាន់អ្នកស្រី អ៊ឹម ចែម

[44] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧២។ ទោះបីជាយ៉ាងនេះក៏ដោយ ចៅក្រមស៊ើបអង្កេតអាចបន្តកិច្ចបាននៅពេលបុគ្គលណាម្នាក់បានបោះបង់សិទ្ធិក្នុងការទទួលបានការគោរពតាមរយៈពេលកំណត់។ ការបោះបង់សិទ្ធិនេះអាចធ្វើឡើងដោយមានវត្តមានរបស់ មេធាវីរបស់បុគ្គលនោះតែប៉ុណ្ណោះ។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧២។

ដោយមិនមានការយល់ព្រមអ្វីទាំងអស់ពីសហភាតាជាតិរបស់គាត់ និងដោយមិនបានផ្តល់ឱកាសឱ្យអ្នកស្រី អ៊ឹម ចែម បានដឹងឮរឿងអ្វីឡើយ នៅក្នុងពេលបង្ហាញខ្លួនដំបូងដែលបានស្នើឡើងនោះទេ។

27. **ចំណុចទីបី** ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា គ្មានការបញ្ជាក់ណាមួយត្រូវបានផ្តល់ជូនអំពីលក្ខណៈនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទេ។ បច្ចុប្បន្នអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជាទាំងស្រុង និងទទួលរងការប៉ះពាល់ពីបញ្ហានៃគ្មាន តម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០៤។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon យល់ឃើញថា ការចោទប្រកាន់ជនសង្ស័យគឺជាបុព្វសិទ្ធិដូចគ្នា រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ ក៏ដោយ ក៏ការចុះហត្ថលេខាលើដីកាកោះហៅអ្នកស្រី អ៊ឹម ចែម ឱ្យមកបង្ហាញខ្លួនក្នុងគោលបំណងធ្វើការចោទប្រកាន់នោះ[45] ត្រូវបានធ្វើឡើងតែដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯងគត់។ អ្នកស្រី អ៊ឹម ចែម មិនបានដឹងហេតុផលដែលសហចៅក្រមស៊ើបអង្កេតជាតិមិនបានចុះហត្ថលេខាលើដីកាកោះហៅគាត់នោះទេ។ នៅក្នុងសេចក្តីសម្រេចរបស់ ស.ច.ស.អ លើសំណើសុំចូលមើលសំណុំរឿង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរម្លឹកថាត្រូវមាន "ភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា" ដែលបង្ហាញថា ជនសង្ស័យអាចទទួលខុសត្រូវលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីអាចចោទប្រកាន់ជននេះបាន[46]។ ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងការចុះហត្ថលេខាលើដីកាកោះ ដែលត្រូវបានចេញទៅឱ្យអ្នកស្រី អ៊ឹម ចែម នោះ ធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងអំពីករណីថាតើមាន*ភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា*នេះដែរឬទេ។ យោងតាមលោកចៅក្រម Blunk និងលោកចៅក្រម យូ ប៊ុនឡេង "នៅក្នុងសំណុំរឿង០០៤ បានឱ្យដឹងថា... ខុសពីសំណុំរឿង០០២ សំណុំរឿង០០៤ មានវិមតិសង្ស័យជាក់ច្បាស់ថាតើជនសង្ស័យនៅក្នុងសំណុំរឿងនេះស្ថិតនៅក្នុងប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

[45] *សូមមើល* ឯកសារ A122/6.1 *ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង* ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤។

[46] សេចក្តីសម្រេចរបស់ ស.ច.ស.អ លើសំណើសុំចូលមើលសំណុំរឿង កថាខណ្ឌ ៤០។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់ ស.ច.ស.អ លើសំណើសុំចូលមើលសំណុំរឿង កថាខណ្ឌ ៤១, ៤៤។

ស្របតាមមាត្រា ២ ស្ដីពីសមត្ថកិច្ចយុត្តាធិការនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែរ ឬ យ៉ាងណា"[47]។ ទោះបីជាសេចក្ដីប្រកាសព័ត៌មានត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០១១ ក៏ដោយ គ្មានអ្វីបង្ហាញឡើយថា បញ្ហានេះមិនត្រឹមត្រូវទេរហូតដល់ពេលបច្ចុប្បន្ន ជាពិសេសចំពោះការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងការចុះហត្ថលេខាលើដីកាកោះហៅអ្នកស្រី អ៊ឹម ចែម នេះ។ ដោយហេតុថា មេធាវីការពារក្ដីពុំមានសិទ្ធិចូលមើលសំណុំរឿងពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០៤ មេធាវីការពារក្ដីពុំអាចផ្ទៀងផ្ទាត់ និងតវ៉ាអំពីការខ្វះភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដែលថា អ្នកស្រី អ៊ឹម ចែម អាចស្ថិតក្នុងចំណាត់ថ្នាក់ជាបុគ្គលទទួលខុសត្រូវលើការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយនោះទេ។ អាស្រ័យហេតុនេះ ជាការសំខាន់ណាស់ដែលសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជាក់អំពីលក្ខណៈនៃការខ្វែងយោបល់គ្នា ដើម្បីធានាថាអ្នកស្រី អ៊ឹម ចែម ត្រូវបានការពារមិនឲ្យរងការប៉ះពាល់ពីកិច្ចការរដ្ឋបាលតុលាការដោយលាក់លៀម មុនពេលដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬសហចៅក្រមស៊ើបអង្កេតណាម្នាក់បំពេញកិច្ចការណាមួយនោះ។

## V. **សំណើសុំ**

យោងតាមហេតុផលទាំងអស់ដូចបានជម្រាបជូនខាងលើ ក្រុមមេធាវីការពារក្ដីសូមស្នើដោយគោរពឲ្យសហចៅក្រមស៊ើបអង្កេតព្យួរដីកាកោះហៅអ្នកស្រី អ៊ឹម ចែម និងសហមេធាវី ដែលចុះកាលបរិច្ឆេទនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ សិន រង់ចាំរហូតដល់សហចៅក្រមស៊ើបអង្កេតដាក់សំណើសុំមោឃភាពលើដីកាកោះហៅអ្នកស្រី អ៊ឹម ចែម និងសហមេធាវីរបស់គាត់ ជូនអង្គបុរេជំនុំជម្រះពិចារណាសម្រេច និងរហូតដល់សហចៅក្រមស៊ើបអង្កេតធ្វើការគូសបញ្ជាក់អំពីការខ្វែងយោបល់គ្នានៅក្នុងកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម នេះសិន។

---

[47] សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ អាចមើលតាមរយៈគេហទំព័រ http://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-civil-parties-case-004។

សូមលោកចៅក្រម មេត្តាទទួលយកសំណើនេះដោយសេចក្តីគោរព។

សហមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម
ចុះហត្ថលេខានាថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤

______________ ______________

ប៊ិត ស៊ាងលីម John R.W.D. JONES QC